# ព្រះជាម្ចាស់ ទ្រង់ជាទីពឹងជ្រក

អ្នកណាដែលនៅជាប់ក្នុងទីកំបាំងនៃព្រះដ៏ខ្ពស់បំផុតនោះនឹងបានជ្រកនៅក្រោមម្លប់នៃព្រះដ៏មានគ្រប់ព្រះចេស្តា។ ឯខ្ញុំ នឹងពោលពីព្រះយេហូវ៉ាថាទ្រង់ជាទីពឹងពំនាក់ ជាបន្ទាយនៃខ្ញុំ គឺជាព្រះនៃខ្ញុំ ហើយខ្ញុំទុកចិត្តនឹងទ្រង់។ (១)

ពីព្រោះខ្ញុំបានយក ព្រះយេហូវ៉ាជាទីពឹងជ្រកនៃខ្ញុំ គឺបានយកព្រះដ៏ខ្ពស់បំផុតជាទីលំនៅរបស់ខ្ញុំ យ៉ាងនោះ នឹងគ្មានសេចក្តីអាក្រក់ណាកើតឡើងដល់ខ្ញុំឡើយ ក៏គ្មានសេចក្តីវេទនាណាមកជិតទីលំនៅរបស់ខ្ញុំដែរ ដ្បិតទ្រង់នឹងបង្គាប់ដល់ពួកទេវតារបស់ទ្រង់ពីដំណើររបស់ខ្ញុំ ដើម្បីឲ្យបានថែរក្សាខ្ញុំ ក្នុងគ្រប់ទាំងផ្លូវរបស់ខ្ញុំ។ (២)

ដ្បិតទ្រង់បានធ្វើជាទីជ្រកកោនឲ្យខ្ញុំ គឺជាប៉មយ៉ាងមាំ ឲ្យរួចពីខ្មាំងសត្រូវ ខ្ញុំនឹងអាស្រ័យនៅក្នុងពន្លារបស់ទ្រង់ជានិច្ច ខ្ញុំនឹងជ្រកនៅទីកំបាំងក្រោមស្លាបរបស់ទ្រង់។ (៣)

ខ្ញុំនឹងងើបភ្នែកមើលទៅឯភ្នំ តើសេចក្តីជំនួយជួយដល់ខ្ញុំមកពីណា? សេចក្តីជំនួយរបស់ខ្ញុំមកតែពីព្រះយេហូវ៉ាទេ គឺជាព្រះដែលបង្កើតផ្ទៃមេឃ និងផែនដី។ ព្រះយេហូវ៉ាទ្រង់ជាព្រះដែលថែរក្សាខ្ញុំ ព្រះយេហូវ៉ាទ្រង់ជាម្លប់នៅខាងស្តាំខ្ញុំ។ (៤)

(១) ទំនុកតម្កើង ៩១: ១-២
(២) ទំនុកតម្កើង ៩១: ៩-១១
(៣) ទំនុកតម្កើង ៦១: ៣-៤
(៤) ទំនុកតម្កើង ១២១: ១-២,៥

**ទំនុកតម្កើង ៩១: ១-២** អ្នកណាដែលនៅជាប់ក្នុងទីកំបាំង
នៃព្រះដ៏ខ្ពស់បំផុតនោះនឹងបានជ្រកនៅក្រោមម្លប់ នៃព្រះដ៏មានគ្រប់
ព្រះចេស្តា។ ២ ឯទូលបង្គំ នឹងពោលពីព្រះយេហូវ៉ាថា ទ្រង់ជាទីពឹងពំនាក់
ជាបន្ទាយនៃទូលបង្គំគឺជាព្រះនៃទូលបង្គំ ហើយទូលបង្គំទុកចិត្តនឹងទ្រង់។

**ទំនុកតម្កើង ៩១: ៩-១១** ពីព្រោះឯងបានថា ព្រះយេហូវ៉ាជាទីពឹង
ជ្រកនៃឯងគឺបានយកព្រះដ៏ខ្ពស់បំផុតជាទីលំនៅរបស់ឯង ១០ យ៉ាងនោះ
នឹងគ្មានសេចក្តីអាក្រក់ណាកើតឡើងដល់ឯងឡើយ ក៏គ្មានវេទនាណាមក
ជិតទីលំនៅរបស់ឯងដែរ ១១ ដ្បិតទ្រង់នឹងបង្គាប់ដល់ពួកទេវតារបស់ទ្រង់
ពីដំណើរឯងឲ្យបានថែរក្សាឯង ក្នុងគ្រប់ទាំងផ្លូវរបស់ឯង។

**ទំនុកតម្កើង ៦១: ៣-៤** ដ្បិតទ្រង់បានធ្វើជាទីជ្រកឲ្យទូលបង្គំ
គឺជាប៉មយ៉ាងមាំ ឲ្យរួចពីខ្មាំងសត្រូវ ៤ ទូលបង្គំនឹងអាស្រ័យនៅក្នុងពន្លា
របស់ទ្រង់ជានិច្ចទូលបង្គំនឹងជ្រកនៅទីកំបាំង ក្រោមស្លាបទ្រង់។

**ទំនុកតម្កើង ១២១: ១-២,៥** ខ្ញុំនឹងងើបភ្នែកមើលទៅឯភ្នំតែសេចក្តី
ជំនួយជួយដល់ខ្ញុំមកពីណា ២ សេចក្តីជំនួយរបស់ខ្ញុំមកតែពីព្រះយេហូវ៉ាទេ
គឺជាព្រះដែលបង្កើតផ្ទៃមេឃ និងផែនដី។ ៥ ព្រះយេហូវ៉ាទ្រង់ជាព្រះដែលថែ
រក្សាអ្នកព្រះយេហូវ៉ាទ្រង់ជាម្លប់នៅខាងស្តាំអ្នក។

**បកប្រែដោយ: ONE- 2 -ONE CAMBODIA**
**អាស័យដ្ឋានៈ # ៣៨ - ៣៨A ផ្លូវលេខ ៣៣៦**
**សង្កាត់ទឹកល្អក់៣ ខ័ណ្ឌទួលគោក**
**រាជធានីភ្នំពេញ ប្រទេសកម្ពុជា**
www.One-2-One world.org
www.derekprince.co.nz PC10